ACCESS 2
Sustainable quality services for all

Australian Aid

ព្រឹត្តិបត្រព័ត៌មានកម្មវិធី

ACCESS 2

កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២

ការវិនិយោគរបស់អូស្ត្រាលី	កម្មវិធីប្រាំឆ្នាំ	៤	១៣
៣០លានដុល្លារអូស្ត្រាលី	២០២៣–២៨	ខេត្តគោលដៅ + រាជធានីភ្នំពេញ	ដៃគូអនុវត្តជាយុទ្ធសាស្ត្រ

អំពីកម្មវិធី



កម្មវិធី ACCESS 2 គឺជាការវិនិយោគទ្វេភាគីរបស់ប្រទេសអូស្ត្រាលីនៅក្នុងសមភាពយេនឌ័រ ពិការភាព ការស្តារលទ្ធភាពពលកម្ម និងបរិយាបន្នសង្គមនៅកម្ពុជា។ អូស្ត្រាលីកំពុងវិនិយោគទឹកប្រាក់ចំនួន៣០លានដុល្លារអូស្ត្រាលី (២០២៣-២០២៨) ដើម្បីលើកកម្ពស់គុណភាពនៃការផ្តល់សេវាប្រកបដោយការសម្របសម្រួល និងបរិយាបន្នភាពសម្រាប់អ្នកនៅរស់រានមានជីវិតពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) និងជនមានពិការភាព។

ក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា កម្មវិធី ACCESS 2 គាំទ្រដល់ការអនុវត្តផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ ដោយបន្តពីកំណែទម្រង់ថ្នាក់ជាតិនៅក្នុងដំណាក់កាលទី១ (២០១៨-២០២៣) បច្ចុប្បន្ននេះ កម្មវិធី ACCESS 2 អនុវត្តកំណែទម្រង់ទាំងនេះនៅថ្នាក់ក្រោមជាតិនៅក្នុងខេត្តគោលដៅចំនួនបួន។

កម្មវិធីនេះពង្រឹងសេវាជួរមុខទាក់ទងនឹងសុខភាព ច្បាប់ សង្គមកិច្ច និងស្តារលទ្ធភាពពលកម្ម ព្រមទាំងគាំទ្រដល់អ្នកនៅរស់រានមានជីវិតពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជនមានពិការភាព សហគមន៍ជនជាតិដើមភាគតិច និងអង្គការតំណាងរបស់ពួកគេ ដើម្បីផ្តល់ជាព័ត៌មានសម្រាប់គោលនយោបាយ និងការរៀបចំផែនការដែលមានផលប៉ះពាល់ដល់ពួកគេ ។

គោលដៅរបស់កម្មវិធី៖ ជនមានពិការភាព និងអ្នកនៅរស់រានពីអំពីហិង្សាទាក់ទងនឹងយេឌ័រ ទទួលបានអត្ថប្រយោជន៍ពីការទទួលបានសេវាប្រកបដោយគុណភាព និងមានការសម្របសម្រួល ។

ផ្នែកជាអាទិភាពចំនួនបួន

- អំពើហិង្សាទាក់ទងនឹងយេនឌ័រ
- បរិយាបន្នពិការភាព
- ការស្តារលទ្ធភាពពលកម្ម
- ការអភិវឌ្ឍជនជាតិដើមភាគតិច

លទ្ធផលវិនិយោគចុងបញ្ចប់កម្មវិធី (EOIO)

EOIO 1

ត្រឹមឆ្នាំ២០២៨ អ្នកផ្តល់សេវាដែលបានជ្រើសរើស នឹងផ្តល់សេវាអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសេវាទាក់ទងនឹងពិការភាពដែលមានគុណភាពកាន់តែប្រសើរដល់អ្នកទទួលផលកាន់តែច្រើនក្នុងខេត្តគោលដៅ ។


EOIO 2

ត្រឹមឆ្នាំ២០២៨ គោលនយោបាយ និងដំណើរការរៀបចំផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានការឆ្លើយតបនឹងអាទិភាពរបស់អ្នកនៅរស់រានពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជនមានពិការភាព ។

លទ្ធផលចម្បង (កក្កដា ២០២៤ – មិថុនា ២០២៥)

៤.៦៦២	១.៨៧៥	៨០	៣១.៤៧៥	៣៧០.០០០+
អ្នកនៅរស់រានពីអំពើហិង្សាទាក់ទងនឹងយេនឌ័រត្រូវបានគាំទ្រ	អ្នកផ្តល់សេវាអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានបណ្តុះបណ្តាល	ទីកន្លែងផ្តល់សេវាអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងស្តារលទ្ធភាពពលកម្ម ត្រូវបានបង្កើតឡើង	អតិថិជនបានទទួលសេវាស្តារលទ្ធភាពពលកម្ម	ជនមានពិការភាពត្រូវបានកំណត់អត្តសញ្ញាណ

យើងធ្វើការនៅទីណាខ្លះ



អគារ ANINA ជាន់ទី៣ ផ្លូវ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

info@access2cambodia.org www.access2cambodia.org

ACCESS 2 ត្រូវបានគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងគ្រប់គ្រងដោយ Abt Global